**Program:** People Story Before Bed

**Topic:** Justin Bieber (ពីក្មេងច្រៀងតាមផ្លូវ ក្លាយជាតារាកំពូលក្នុងមួយរំពិចភ្នែក)

**Categories:** Successful People

**Publish Date:**

**Content by:** Prey Reung



---

**Hook**

សូមស្វាគមន៍មកកាន់ CamID Podcast

ពីក្មេងច្រៀងតាមផ្លូវសោះ បែរក្លាយជាតារាកំពូលក្នុងមួយរំពិចភ្នែក។

ធ្លាប់ដែរទេ? អ្វីដែលយើងមិនដែលរំពឹងថាវានឹងជោគជ័យនោះ
បែរជាធ្វើអោយយើងជោគជ័យដោយមិនដឹងខ្លួន!

ថ្ងៃនេះ ព្រៃរឿងនឹងលើកយកជីវិតរបស់កំពូលដារាចម្រៀងវ័យក្មេងម្នាក់ ដែលល្បីល្បាញជុំវិញពិភពលោក
មកបកស្រាយ។ ដែលតារាចម្រៀងម្នាក់នោះគឺមានឈ្មោះថា Justin Bieber!

**Intro**

ព្រៃរឿងដឹងហើយថា មានប្រិយមិត្តរបស់ព្រៃរឿងមួយចំនួន ក៏ជាអ្នកគាំទ្រដារាវ័យក្មេងម្នាក់នេះដែរ
ហើយប្រាកដជាមានអ្នកខ្លះ បានដឹងពីប្រវត្តិខ្លះៗ អំពីដារាចម្រៀងរូបនេះហើយដែរ។

តារាក្មេងវ័យរូបនេះ មិនដែលគិតថាខ្លួន ក្លាយទៅជាដារាលំដាប់ពិភពលោកដូចថ្ងៃនេះនោះឡើយ ក៏ប៉ុន្តែ
ដោយសារតែគេ គឺជាក្មេងម្នាក់ដែលមានទេពកោសល្យផ្នែកតន្ត្រី តាំងពីគេនៅតូចមកម្លេះ ណាមួយ
បូកបន្ថែមជាមួយសម្រស់របស់គេថែមទៀត ទើបធ្វើអោយគេ ក្លាយជាតារាម្នាក់
ដែលអាចទាញចំណាប់អារម្មណ៍យុវជន និងយុវនារីជាច្រើនលើពិភពលោក។

ក្មេងម្នាក់នេះ ត្រូវបានគេស្គាល់ថាជាដារាចម្រៀងម្នាក់ ដែលមិនបានហ្វឹកហាត់ ការច្រៀងត្រឹមត្រូវនោះទេ

ប៉ុន្តែគេបានក្លាយជាតារាម្នាក់ ដែលលិចធ្លោក្នុងជីវិតជាយុវវ័យ។

ដូចនេះ កុំអោយខាតពេលយូរ មកស្តាប់ព្រៃរឿងបកស្រាយទាំងអស់គ្នា។

**Body**

តារាមុខស្រស់ សញ្ជាតិកាណាដា វ័យក្មេងរូបនេះ មានឈ្មោះពេញថា Justin Bieber កើតនៅថ្ងៃទី១
ខែមិនា ឆ្នាំ១៩៩៤ នៅក្នុងរដ្ឋ Stratford ទីក្រុង Ontario នៃប្រទេសCanada។

Justin ធំដឹងក្តីមក ក៏តែសារតែម្តាយរបស់គេឈ្មោះPattie Malletteម្នាក់តែប៉ុណ្ណោះ ព្រោះឪពុករបស់
Justin ឈ្មោះJeremy Justin បានទៅមានគ្រួសារថ្មី ជាមួយប្រពន្ធថ្មីរបស់គាត់តាំងពីJustin
នៅតូចម្លេះ។

តែយ៉ាងណានៅឆ្នាំ២០១០ ពេលគឺJustinមានអាយុឆ្នាំ ពេលនោះរូបគេបានបញ្ជាក់ថា ទំនាក់ទំនងរបស់Justinជាមួយឪពុករបស់គេគឺជិតស្និទ្ធ។

នៅពេលដែលគេនៅតូច ឪពុករបស់គេ ថែមទាំងធ្លាប់បង្រៀនគេ អោយចេះលេងហ្គីតាទៀតផង ហើយJustinក៏មានរូបសាក់ ដែលដូចគ្នាទៅនឹងសាក់ឪពុករបស់គេផងដែរ។

នៅតូចJustinគឺជាក្មេងម្នាក់ ដែលចូលចិត្តលេងឧបករណ៏មួយចំនួនភ្លេងដូចជា ស្គ ព្យាណូ ហ្គីតា និងត្រុំផ្លុំជាដើម។

Justin ជាក្មេងម្នាក់ដែលមានចំណាប់អារម្មណ៏ខាងតន្ត្រីមែនតែន ប៉ុន្តែ គេមិនដែលមានក្តីស្រម៉ៃថា គេនឹងក្លាយជាតារានៅថ្ងៃណាមួយនោះទេ។

ក្រោយមកនៅឆ្នាំ២០០៧ Justinបានចូលរួមកម្មវិធីប្រកួតចម្រៀងមួយនៅក្នុងស្រុក ហើយក៏ទទួលបានចំណាត់ថ្នាក់លេងរៀងទី២ផងដែរ ដែលនេះគឺផ្លូវមួយដែលនាំអោយគេក្លាយជាតារាមួយដែរ។

រឿងដែលអោយមិនគួរអោយជឿនោះគឺ ម្តាយរបស់Justin បានផុសវីដេអូដែលគេសម្តែងលើឆាក និងវីដេអូដែលគេច្រៀងនៅផ្ទះ ចូលក្នុងបណ្តាញសង្គមYoutube ក្នុងគោលបំណង គ្រាន់តែចែករំលែកទៅកាន់មិត្តភក្តិ និងសាច់ញាតិរបស់គេតែប៉ុណ្ណោះ ប៉ុន្តែត្រឹមតែរយះពេលតែ១ខែសោះ វីដេអូរបស់Justin បានទាញចំណាប់អារម្មណ៏អ្នកលេងយូធូប ចូលមកទស្សនារាប់លាននាក់។

ពេលនោះហើយ ដែលវីដេអូរបស់Justinមានអ្នកលើកស្ទួយសិល្បះចម្រៀងម្នាក់ ឈ្មោះScott Braun បានអញ្ជើញJustinទៅថតសម្លេងនៅទីក្រុងAtlanta រដ្ឋGeorgia នៃសហរដ្ឋអាមេរិក។

គ្រានោះJustinបានជួបតារាចម្រៀងសញ្ជាតិអាមេរិកដ៏ល្បីល្បាញម្នាក់ ឈ្មោះថាUsher។ ដោយសារតែJustinមានជុងផ្នែកតន្ត្រីតាំងពីកំណើត និងច្រៀងពិរោះផងនោះ Usherក៏ព្រមជួយJustin អោយចុះកុងត្រា ធ្វើជាអ្នកចម្រៀងទាំងវ័យក្មេង នៅចុងឆ្នាំ២០០៨។

មិនយូរប៉ុន្មាន នៅឆ្នាំ២០០៩ Justin ក៏បញ្ចេញអាលប៊ុមរបស់គេ ជាលើកដំបូង ដែលមានចំណងជើងថា My World ។

ត្រឹមតែរយៈពេលតែមួយសប្តាហ៍តែប៉ុណ្ណោះ Justin លក់បានសរុប១៣៧០០០ CDឯនោះ។ លុះដល់ឆ្នាំ២០១០ Justinបានបញ្ចេញអាល់ប៊ុមទី២របស់គេ គឺ My World2.0 ដែលមាន១០បទនៅក្នុងនោះ។ អាល់ប៊ុមនេះបានធ្វើអោយគេកាន់តែល្បីល្បាញខ្លាំងជាងមុនទៅទៀត។

មួយវិញទៀត នៅឆ្នាំ២០១១ បទចម្រៀងរបស់Justinចំណងជើងថា Never Say Never ក៏បានបញ្ចេញជាមួយនឹងអាល់ប៊ុម Holiday រីឯបទមួយទៀតគឺMistletoe ក៏ចេញនៅឆ្នាំតែមួយដូចគ្នា។

គួរបញ្ជាក់ផងដែរថាបទ Never say Never គឺជាបទច្រៀង ដែលផលិតឡើង ក្រោមការសហការណ៍ជាមួយនឹងរឿង Karate Kid ម្យ៉ាងវិញទៀតបទនេះ ធ្វើអោយរឿងនេះ រកចំណូលបានដល់ទៅ៧៣លានដុល្លាឯនោះ។

ក្រោយស្នាដៃរបស់គេបានបញ្ចេញរួចអស់ Justin កាន់តែទទួលបានអ្នកគាំទ្រជាច្រើនកុះករថែមទៀត ជាពិសេស គឺនារីដែលជាយុវវ័យជាច្រើន បានយកJustinធ្វើជានិមិត្តរូបរបស់ខ្លួនផងដែរ នេះក៏ដោយសារតែJustinមានសម្រស់ស្រស់សង្ហា និងពោរពេញទៅដោយសមត្ថភាពនៅគ្រានោះ។

អ្វីដែលកាន់តែគួរអោយចាប់អារម្មណ៍ គឺថាកាលពីឆ្នាំ២០០៩ និងឆ្នាំ២០១១ Justinត្រូវបានគេអញ្ជើញអោយទៅប្រគុំតន្ត្រីអោយអតីតប្រធានាធបតី លោកBarack Obamaថែមទៀតផង។

ដោយសារតែអ្នកគាំទ្រកាន់តែច្រើនទៅៗ Justin កាន់តែព្យាយាមផលិតបទចម្រៀងជាច្រើនថែមទៀត ពោលគឺនៅឆ្នាំ២០១២ Justin បានបញ្ចេញអាល់ប៊ុមថ្មីមួយទៀត ដែលមានចំណងជើងថា Believe ដែលអាល់ប៊ុមនេះលក់ដាច់ជាងមុនដល់ទៅ៣៧៤០០០ CDឯនោះ។

នេះគឺជាតួលេខមួយដែលច្រើនបំផុតមិនធ្លាប់មាន។

នៅឆ្នាំ២០១៥ Justin បានត្រឡប់មកវិញជាមួយនឹងការផ្លាស់ផ្តូថ្មី នៅក្នុងអាល់ប៊ុម Purpose របស់គេ។ នេះគឺជាលើកទី៥ នៃការលក់អាល់ប៊ុមរបស់គេ ប៉ុន្តែលើកនេះ ចំនួនសរុបនៃការលក់គឺដល់ទៅរាប់លាន នៅឯសហរដ្ឋអាមេរិក។ មិនត្រឹមតែប៉ុណ្ណោះ គ្រានោះJustinក៏បានទទួលពានរង្វាន់ពីGrammy Awardsទៀតផង។

ក្រៅពីនេះ នៅបទចម្រៀងរបស់Justin មួយចំនួនទៀត ដែលមានអ្នកទស្សនារាប់រយលានដងនៅក្នុងYoutube ផងដែរ មានដូចជា បទ One Time បទBaby និងបទ What do you mean? ហើយក៏នៅមានបទល្បីៗជាច្រើនទៀត នៅក្នុងយូធូបរបស់គេ។អ្នកទាំងអស់គ្នាអាចចូលទៅស្តាប់បាន។

យ៉ាងណា Justin មិនមែនល្បីល្បាញរហូតនោះទេ គេក៏មានរឿងអាស្រូវមួយចំនួនដែរ។ កាលពីឆ្នាំ២០១១ ដែលកាលនោះ Justin មានវ័យជំទង់នៅឡើយ មាននារីម្នាក់ បានចេញមុខជាសារធារណៈចោទ Justin ថាគេគឺជាឪពុករបស់កូននាង ក៏ប៉ុន្តែ ក្រោយពីការធ្វើតេស្តDNA រួច Justinមិនមែនជាឪពុកនោះទេ។

ដោយសារតែJustinល្បីល្បាញ ក្នុងវ័យក្មេងពេក ទើបធ្វើអោយគេបាត់បង់ភាពម្ចាស់កាលលើខ្លួន តួយ៉ាងនៅឆ្នាំ២០១៣ អ្នកជិតខាងម្នាក់បានចោទ Justin ជាសារធារណៈថាJustin បានស្តោះទឹកមាត់ដាក់គេ និងនិយាយពាក្យគំរាមគំហែងទៀតផង។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ Justin ត្រូវបានប៉ូលិសចាប់ខ្លួន ពីបទប្រណាំងឡានលើផ្លូវសារធារណៈ និងបើកបរដោយស្ថានភាពស្រវឹង។ Justinត្រូវបានឃុំខ្លួនអស់មួយរយះ និងបង់ថ្លៃផាកពិន័យជាទឹកប្រាក់ចំនួន២៥០០ដុល្លា។

កាលនោះ Justin ទទួលរងឥទ្ធិពលជាច្រើន ពីពាក្យរិះគន់របស់អ្នកគាំទ្ររបស់គេ មានអ្នកខ្លះស្អប់ អ្នកខ្លះជេ និង ឈប់គាំទ្រគេ។

បែបនេះJustin ក៏ប្រឈម នឹងជម្ងឺបាក់ទឹកចិត្ត។ Justin ត្រូវចំណាយពេលអស់ជាយូរ ក្នុងការព្យាបាលជម្ងឺមួយនេះ ហើយក៏បានផុសពីអារម្មណ៏ផ្ទាល់ខ្លួន របស់គេនៅក្នុងបណ្តាញសង្គមInstagramថា គេមានអារម្មណ៏ថាឃ្លាតឆ្ងាយពីមនុស្សជុំវិញខ្លួនរបស់គេ និងព្យាយាមតទល់ជាមួយជម្ងឺនេះជាច្រើនមកហើយ ក៏ប៉ុន្តែ គេនៅតែត្រឡប់មកវិញ ដើម្បីផ្តល់ក្តីសង្ឃឹមអោយអ្នកគាំទ្រគេដដែរ ព្រោះថាមានអ្នកគាំទ្រចាំលើកទឹកចិត្តគេរហូតមក។

បើនិយាយពី ជីវិតស្នេហារបស់Justin វិញគឺថាJustinបរាជ័យជាច្រើនមកហើយ ទោះបីជាគេមានរូបសម្រស់ស្អាតយ៉ាងណាក៏ដោយ ជាក់ស្តែងនៅឆ្នាំ២០១០ Justin បានធ្វើអ្នកគាំទ្រស្រីជាច្រើនអ្នកខូចចិត្ត ក៏ព្រោះតែគេមានស្នេហាជាលើកដំបូង ជាមួយជាពចម្រៀងស្រីឈ្មោះថា Selena Gomez។

ទោះបីជាស្នេហារបស់គេទាំងពីរ មានភាពល្អោកល្អើនជាសារជារណះក៏ដោយ ស្នេហារបស់ពួកគេទាំងពីរ នៅតែរកាំរកុះ ព្រោះអ្នកគាំទ្ររបស់ Selena មិនពេញ Justin នោះទេហើយ ថែមទាំងផុសសារគម្រាមកំហែងដល់ Selena ថែមទៀតផង។

ពួកគេទាំងពីបានបែកកបាក់គ្នានៅឆ្នាំ២០១២ ប៉ុន្តែនៅឆ្នាំ២០១៧ពួកគេបាន ត្រូវបានសារជារណជន ប្រទះឃើញម្តងទៀត។ មានចចាមរាមខ្លះថាពួកគេត្រូវគ្នាវិញ។ តែ Selena និងJustin ក៏បានដាច់ស្រលះគ្នាតាំងពីពេលនោះមក។

ងាកមកមើលគូស្រករថ្មីរបស់ Justin វិញ គឺឈ្មោះ Hailey Baldwin ដែលជាតារាសម្តែង និងដើរម៉ូត។ Justin ស្គាល់ Hailey តាំងពីគេនៅស្រលាញ់Selenaមកម្លេះ តែពេលនោះ ស្គាល់គ្នាក្នុងនាមជាមិត្តភក្តិតែប៉ុណ្ណោះ។

Justin និង Hailey បានស្រលាញ់នៅឆ្នាំ២០១៨។ក្រោយពី បានភ្ជាប់ពាក្យបានពីរខែ ពួកគេទាំងពីរ បានរៀបការជាមួយគ្នានៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០។

ព្រៃរឿងសូមបញ្ជាក់ផងដែរថា មុននឹងគេមានថ្ងៃនេះ គឺJustin និងHailey ស្គាល់គ្នាតាំងពីHaileyនៅជាអ្នកគាំទ្ររបស់Justinមកម្លេះ។

បច្ចុប្បន្ន Justin រស់នៅផ្ទះវីឡាដ៏ធំស្កឹមស្កៃ ជាមួយភរិយារបស់គេ នៅឯប្រទេសកាណាដា ជាមួយនឹងចំណូលសរុបរបស់គេខ្ទង់ ៣០០លានដុល្លាសហរដ្ឋអាមេរិក។ ចំនួនទឹកប្រាក់នេះ បាននាំអោយគេក្លាយជាមហាសេដ្ឋីវ័យក្មេងមួយរូប ក្នុងចំណោមតារាវដទៃ។

ថ្មីៗនេះ កាលពីចុងឆ្នាំ២០២០ Justin បានត្រឡប់មកវិញសារជាថ្មីម្តងទៀត ជាមួយនឹងអាល់ប៊ុមថ្មីក្រោមចំណងជើងថា Changes ដែលមានបទសរុប ១៦បទ ហើយបទដែលមានចំនួនអ្នកទស្សនាច្រើនជាងគេ មានដូចជា បទ Yummy និងបទ Intention។

ការត្រឡប់មកវិញម្តងនេះ ឃើញថាJustinមានភាពចាស់ទុំច្រើនជាងមុន គឺគេមិនដូចមុនទៀតឡើយ។

**Ending**

ជាចុងក្រោយ តាមរយៈរឿងរ៉ាវនេះ

ចំណុចដែលអ្នកទាំងអស់គ្នាគួរតែស្វែងយល់ និងយកគំរូតាម គឺយើងត្រូវចេះស្វែងរកទេពកោលស្សរបស់ខ្លួន និងស្គាល់ពីអ្វីដែលយើងស្រលាញ់ពិតប្រាកដ។ កាលដែលយើងរកឃើញហើយ យើងត្រូវតែចេះប្រើប្រាស់ និងអភិវឌ្ឍវា នោះវានឹងបានផលនៅថ្ងៃណាមួយជាក់ជាមិនខាន។

ទោះបីជាយ៉ាងណាក៏ដោយ មនុស្សគ្រប់រូបគឺមិនមាននរណាម្នាក់ល្អឥតខ្ចោះនោះទេ តួយ៉ាងដូចជា Justin ជាដើម គឺរូបគេមានគុណវិបត្តិគួរឲ្យកត់សម្គាល់ដែរ ប៉ុន្តែអ្វីដែលគួរឲ្យគោរពនោះគឺ ការចេះកែប្រែកំហុស ហើយក៏សាងរឿងល្អឡើងវិញ ដែលជាអ្វីដែលមនុស្សគ្រប់រូបគួរតែមាន។

Link and Resources

https://www.biography.com/

https://www.britannica.com/

https://www.eonline.com/news/